002/19-09-2007-ECCC/TC
E1/49

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 22 / 03 / 2012
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៣៧

រៀបចំដោយ: ឌុច ផារី និង Natacha WEXELS-RISER

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូ រ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណា, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី , លោក ដាវ អានសាន, លោកស្រី Natacha WEXELS-RISER |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Vincent DE WILDE D'ESTMAEL, លោក ច័ន្ទ តារារស្មី, លោក វ៉េង ហ៊ត់, លោក Dale LYSAK |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ (សហមេធាវី), លោក Michiel Pestman (សហមេធាវី), លោក Andrew IANUZZI |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម (សហមេធាវី) លោក Michael Karnavas (សហមេធាវី) |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន (សហមេធាវី),លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ (សហមេធាវីនាំមុខ), លោកស្រី Elisabeth Simonneau-Fort (សហមេធាវីនាំមុខ), លោក ឡោ ជុនធី, លោកស្រី ស៊ិន សុវ៉ន, លោក ហុង គឹមសួន, លោកស្រី ជេត វណ្ណលី |
| សាក្សី៖ មិនមាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក កូវ កែវរតនៈ |
| ផ្សេងៗ៖ លោក Philippe GOUT |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទ ១៥ ខែ មីនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.១៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.២០ | បញ្ចប់ម៉ោង៖ ១៣.៤៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.២០ | បញ្ចប់ម៉ោង៖ ១៤.៥០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៥ ម៉ោង |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការជំទាស់របស់មេធាវីការពារក្តីទៅលើឯកសាររបស់សហព្រះរាជអាជ្ញា | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន | ៩.០៣<br>៩.១៥<br>៩.៥៩ | ៩.១៥<br>៩.៥៩<br>១០.២៦ |
| ការពិភាក្សាអំពីវិធីសាស្ត្រនៃការស្តាប់សក្ខីកម្មរបស់អ្នកជំនាញ Ben Kiernan (TCE-38) | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា | ១០.៥១ | ១៦.១៥ |
| ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ១០.២៩<br>១២.១៨ | ១០.២៩<br>១២.១៨ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការជំទាស់របស់មេធាវីការពារក្ដីទៅលើឯកសាររបស់សហព្រះរាជអាជ្ញា</u>**

មេធាវីការពារក្ដី នួន ជា, អៀង សារី និង ខៀវ សំផន បង្ហាញនូវការជំទាស់របស់ខ្លួនទៅលើឯកសារដែលបានដាក់ដោយសហព្រះរាជអាជ្ញា ។

**<u>ការពិភាក្សាអំពីវិធីសាស្ត្រនៃការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញ Ben Kiernan (TCE-38)</u>**

មេធាវីការពារក្ដីទាំងអស់ជំទាស់ទៅនឹងការស្ដាប់សក្ខីកម្មរបស់សាស្ត្រាចារ្យ Ben Kiernan តាមរយៈប្រព័ន្ធសោតទស្សន៍ ។ សហព្រះរាជអាជ្ញាបញ្ជាក់ថា សហព្រះរាជអាជ្ញាក៏មានបំណងស្ដាប់សក្ខីកម្មរបស់អ្នកជំនាញរូបនេះដោយផ្ទាល់ផងដែរ ប៉ុន្តែដោយសារភាពមិនអាចមកបានរបស់អ្នកជំនាញ ដូច្នេះសហព្រះរាជអាជ្ញាស្នើសុំស្ដាប់សក្ខីកម្មរបស់អ្នកជំនាញរូបនេះតាមរយៈប្រព័ន្ធសោតទស្សន៍ ។ មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីគាំទ្រសំណើរបស់សហព្រះរាជអាជ្ញា ។

**<u>ការពិភាក្សាអំពីកាលវិភាគសវនាការ</u>**

អង្គជំនុំជម្រះប្រកាសនូវកាលវិភាគសវនាការសម្រាប់សប្ដាហ៍ក្រោយ៖

- ថ្ងៃ ច័ន្ទ និងថ្ងៃ ពុធ អង្គជំនុំជម្រះនឹងធ្វើសវនាការតែពេលព្រឹកប៉ុណ្ណោះ ដោយស្ដាប់សក្ខីកម្មរបស់ជនជាប់ចោទ នួន ជា ។ អង្គជំនុំជម្រះនឹងមិនធ្វើសវនាការនៅពេលរសៀលនោះទេ ។
- ថ្ងៃ អង្គារ និងថ្ងៃ ព្រហស្បតិ៍ អង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មរបស់សាក្សី កាំង ហ្កេចអ៊ាវ (ពេញមួយថ្ងៃ) ។

**<u>ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមតាមការស្នើសុំ (លិខិតលះបង់សិទ្ធិត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (ម៉ោង ១០.២៩) និង នួន ជា (ម៉ោង ១២.១៨) ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោទស្សន៍ទៅបន្ទប់រង់ចាំ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី, នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ៩ ព្រឹក នៅថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១២។

| <u>ការលើកពេលវេលាសវនាការបន្ត៖</u> |
|---|
| សវនាការនឹងបន្តនៅថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១២ វេលាម៉ោង ៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ផារី** Natacha WEXELS-RISER